ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២១៦៨៧ អពដ

GENERAL DEPARTMENT OF TAXATION

# សារលិខិតចូលរួមមរណទុក្ខ

**គោរពជូន**
**លោកជំទាវ ហង់ តារី ភរិយានៃសពឯកឧត្តម អ៊ឹម សិទ្ធី**
**និងក្រុមគ្រួសារ**

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ និងក្នុងនាមខ្ញុំផ្ទាល់ យើងខ្ញុំទាំងអស់គ្នាមានសេចក្ដីក្តុកក្តួល រន្ធត់ឥតឧបមា ដោយបានទទួលដំណឹងថា **ឯកឧត្តម អ៊ឹម សិទ្ធី** សមាជិកគណៈកម្មាធិការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ត្រូវជាឪពុក និងឪពុកក្មេក បានទទួលមរណភាពកាលពីវេលាម៉ោង ០៤:៤៥ នាទីព្រឹក ថ្ងៃសុក្រ ០៥ រោច ខែមិគសិរ ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ក្នុងជន្មាយុ ៧០ ឆ្នាំ ដោយរោគាពាធ។

ការបាត់បង់**ឯកឧត្តម អ៊ឹម សិទ្ធី** គឺជាការបាត់បង់ស្វាមី បិតា បិតាក្មេក ជីតា ជាទីគោរពស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ និងទឹកចិត្តសណ្ដោសប្រណីដ៏ថ្លៃថ្លា។

ស្ថិតក្នុងសមានទុក្ខ វិយោគសោកស្ដាយរកទីបំផុតគ្មាននាឱកាសនេះ យើងខ្ញុំសូមចូលរួមសម្ដែងមរណទុក្ខ និងក្ដីអាឡោះអាល័យ ជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ និងសូមបួងសួងសូមវិញ្ញាណក្ខន្ធ**ឯកឧត្តម អ៊ឹម សិទ្ធី** ឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោក**ជំទាវ ហង់ តារី** មេត្តាទទួលនូវសេចក្ដីគោរពរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃសុក្រ ០៥ រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី០៨ ខែធ្នូ គ.ស. ២០១៧

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

ព្រះរាជាណាចក្រកម្ពុជា
អគ្គនាយកដ្ឋានពន្ធដារ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh